# ទិដ្ឋាការចេញចូលច្រើនដងក្នុងគោលបំណងពាណិជ្ជកម្ម

ទិដ្ឋាការនេះសម្រាប់សាមីជនមានសញ្ជាតិខ្មែរ ឬមានសញ្ជាតិបណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិក (សម្រាប់សញ្ជាតិចិន ហ្វីលីពីន វៀតណាមមាននីតិវិធីខុសពីនេះ) គោលបំណង "ពាណិជ្ជកម្ម (កិច្ចប្រជុំ អង្កេតទីផ្សារ វគ្គបណ្តុះបណ្តាលដោយមិនទទួលប្រាក់ចូល ពិព័រណ៍ជាដើម)"។ (សូមចូលមើលសម្រាប់ប្រទេសដែលអាចស្នើសុំបាន)

ទិដ្ឋាការនេះមានសុពលភាពអតិបរមា៣ឆ្នាំ (ករណីខ្លះទទួលបាន១ឆ្នាំ) និងអាចស្នាក់នៅម្តងរយៈពេល ៩០ថ្ងៃ។

**★★★ អ្នកដែលអាចដាក់ពាក្យបាន ★★★**

បុគ្គលដែលមានឋានៈជា (១) នាយក ឬខ្ពស់ជាងនេះ, (២) បុគ្គលិកពេញម៉ោងដែលបានធ្វើការលើសពី១ឆ្នាំនៅក្នុងក្រុមហ៊ុន/ស្ថាប័នមួយក្នុងចំនោមក្រុមហ៊ុន/ស្ថាប័នខាងក្រោម, និងប្តីប្រពន្ធ ឬកូនរបស់ពួកគេ៖

១. ជាបុគ្គលិកសហគ្រាសសាធារណៈគ្រប់គ្រងដោយរដ្ឋ

២.ក្រុមហ៊ុនឯកជនដែលមាននៅលើទីផ្សារភាគហ៊ុន

៣.ជាបុគ្គលិកក្នុងក្រុមហ៊ុនដែលជាសមាជិកនៃសមាគមពាណិជ្ជកម្មជប៉ុន (JBAC) និង មានការិយាល័យក្រុមហ៊ុននៅប្រទេសជប៉ុន

៤.ជាបុគ្គលិកក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬសាខានៃក្រុមហ៊ុនបណ្តាក់ទុន ឬសហវិនិយោគ ជាមួយក្រុមហ៊ុនជប៉ុនដែលមាននៅលើទីផ្សារភាគហ៊ុន

៥.ជាបុគ្គលិកនៃក្រុមហ៊ុនដែលមានទំនាក់ទំនងការងាររយៈពេលវែងជាមួយក្រុមហ៊ុនជប៉ុនដែលមាននៅលើទីផ្សារភាគហ៊ុន

| | | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|---|
| ១ | ☐ | លិខិតឆ្លងដែន ច្បាប់ដើម | · មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>· ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ ច្បាប់ដើម<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | · រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>· បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |

| | | | |
|---|---|---|---|
| ៣ | □ | លិខិតបញ្ជាក់ការងារ | · បញ្ជាក់៖ មុខតំណែង រយៈពេលនៃការងារ ប្រាក់បៀវត្សរ៍ ។ល។ (មិនមានកំណត់ទម្រង់) |
| ៤ | □ | ឯកសារបញ្ជាក់(១)ដល់(៥) | ★★★ អ្នកដែលអាចដាក់ពាក្យបាន ★★★ |
| ៥ | □ | លិខិតស្នើរសុំទិដ្ឋាការចេញចូលច្រើនដង | · សរសេរពីមូលហេតុនៃការស្នើសុំទិដ្ឋាការចេញចូលច្រើនដង។ (មិនមានកំណត់ទម្រង់) |
| ៦ | □ | ឯកសារបញ្ជាក់ពីទំនាក់ទំនង | · សម្រាប់ករណីប្ដីប្រពន្ធ/កូនដាក់ពាក្យស្នើសុំទិដ្ឋាការចេញចូលច្រើនដងក្នុងពេលជាមួយគ្នា។<br>(សូមសរសេរបញ្ចូលទាំងមូលហេតុក្នុងលិខិតស្នើរសុំទិដ្ឋាការចេញចូលច្រើនដងខងលើ) |